# គម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា
## ផែនការសកម្មភាពសង្គម និងបរិស្ថាន

1. ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ នឹងអនុវត្តគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា ដោយមានការចូលរួមពីក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួនដូចជា៖ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងធនាគារពិភពលោកតំណាងដៃគូអភិវឌ្ឍ ដែលផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា

2. ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ នឹងអនុវត្តសកម្មភាព និងវិធានការចាំបាច់ដែលត្រូវអនុលោមតាមឯកសារស្តង់ដាសង្គម និងបរិស្ថាន របស់ធនាគារពិភពលោក ដោយផែនការសកម្មភាពសង្គម និងបរិស្ថាន បានរៀបចំឲ្យមានសម្ភារៈ និងឧបករណ៍សម្រាប់អនុវត្តសកម្មភាព និងវិធានការ ឆ្លើយតបនឹងបញ្ហាសង្គម និងបរិស្ថាន តាមពេលវេលាកំណត់របស់គម្រោង

3. ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ នឹងអនុវត្តតាមរាល់ឯកសារសង្គម និងបរិស្ថានផ្សេងទៀត ក្នុងដែនកំណត់ឯកសារក្របខ័ណ្ឌសង្គម និងបរិស្ថាន របស់ធនាគារពិភពលោក។ ផែនការសកម្មភាពសង្គម និងបរិស្ថាន ត្រូវបានអនុវត្តគ្របដណ្តប់លើឯកសារដូចជា៖ ផែនការគ្រប់គ្រងសង្គម និងបរិស្ថាន (ESMP) ផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ (RAP) ក្របខ័ណ្ឌអភិវឌ្ឍជនជាតិដើមភាគតិច (IPDF) និងផែនការផ្សារភ្ជាប់ជាមួយអ្នកពាក់ព័ន្ធ (SEP) ដោយមានតារាងពេលវេលាដាក់លាក់នៅក្នុងឯកសារខាងលើ

4. ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើការសម្រេចឲ្យបានក្នុងការអនុវត្តផែនការសកម្មភាពសង្គម និងបរិស្ថាន ទោះបីជាសកម្មភាពនេះត្រូវបានអនុវត្តដោយក្រសួងស្ថាប័ន ឬអង្គភាពពាក់ព័ន្ធខាងលើក៏ដោយ

5. ការអនុវត្តសកម្មភាព និងវិធានការដែលបានរៀបចំនៅក្នុងផែនការសកម្មភាពសង្គម និងបរិស្ថាន ត្រូវត្រួតពិនិត្យ និងរាយការណ៍ជូនធនាគារពិភពលោក ដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការបំពេញនូវលក្ខខណ្ឌកិច្ចព្រមព្រៀងហិរញ្ញប្បទាន ហើយធនាគារពិភពលោក នឹងចុះត្រួតពិនិត្យ វាយតម្លៃអំពីវឌ្ឍនភាព និងលទ្ធផលនៃការចាត់វិធានការលើការងារសង្គម និងបរិស្ថាន

6. ផែនការសកម្មភាពសង្គម និងបរិស្ថាននឹងត្រូវបានកែសម្រួលធ្វើបច្ចុប្បន្នភាពតាមស្ថានភាពជាក់ស្តែងពេលចាប់ផ្តើមដំណើរការគម្រោង ដោយមានការព្រមព្រៀងរវាងធនាគារពិភពលោក ជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួល និងលទ្ធភាពបទបែនបានចំពោះបញ្ហាយថាហេតុ និងដើម្បីឆ្លើយតបទៅនឹងដំណើរការអនុ

វត្តគម្រោងជានាសង្គតិភាពជាមួយនឹងផែនការសកម្មភាពសង្គម និងបរិស្ថានដែលបានកំណត់។ នៅក្នុងកាលៈទេសៈខ្លះ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវឯកភាពគ្នាក្នុងការផ្លាស់ប្តូរ ឬកែសម្រួល ដើម្បីធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព ជាមួយធនាគារពិភពលោក ហើយកិច្ចព្រមព្រៀងនោះត្រូវបានរៀបចំជាលិខិតផ្លូវការរវាងក្រសួងស្ថាប័នអនុវត្តគម្រោង ជាមួយធនាគារពិភពលោក និងត្រូវផ្សព្វផ្សាយជាសធារណៈនូវឯកសារស្តីពីផែនការសម្មភាពសង្គម និងបរិស្ថានថ្មី

7. ករណីគម្រោងមានការប្រែប្រួល ដោយសារបញ្ហាយថាហេតុ ឬលទ្ធផលនៃការអនុវត្តគម្រោងមានការប្រែប្រួលដោយសារមានហានិភ័យ និងផលប៉ះពាល់ខ្លាំង ក្រសួងស្ថាប័នអនុវត្តគម្រោង នឹងផ្តល់នូវហិរញ្ញប្បទានបន្ថែមក្នុងករណីចាំបាច់ ដើម្បីអនុវត្តសកម្មភាព និងវិធានការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ទាំងឡាយនោះ។